ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

[redacted]

សាលាដំបូង
ខេត្តបន្ទាយមានជ័យ

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌលេខ : ៣៤៩
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១
ជំនុំជម្រះថ្ងៃទី : ០៣-សីហា-២០២១
សាលក្រមលេខ : ៣៧"ឈ"/២៤៨
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ នាថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ពីរ និងសាមសិបនាទីរសៀល។

បានប្រកាសសាលក្រមជាសាធារណៈ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ប្រាំបួនព្រឹក។

## សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

- លោក [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

- លោក [redacted] ជាក្រឡាបញ្ជី

## មេធាវី

- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សម្បត្តិ
- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សម្បត្តិ

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៩ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] **សម្បត្តិ** ភេទប្រុស អាយុ ៤០ឆ្នាំ សញ្ជាតិខ្មែរ ជានីតិជន ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ស្ពឺ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិគីឡូ១៣ (ឃុំមិនស្គាល់) ស្រុកសំពៅលូន ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] បៀង "រស់" ម្ដាយឈ្មោះ [redacted] ឡាំ "រស់" ប្រពន្ធឈ្មោះ [redacted] សុឃីម មានកូនចំនួន០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ២៤៩ ព្រ.ទ||| "យ"/២១ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១)

ជាប់ចោទពីបទ **"ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន"** ប្រព្រឹត្តនៅចំណុចភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

## អង្គហេតុកើតឡើងមានដូចតទៅ :

កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ២១:០០ នាទី នៅចំណុចភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កម្លាំងអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ សហការជាមួយអង្គភាពវរៈសេនាតូច នគរបាលការពារព្រំដែនគោក៨១៥ និងកម្លាំងប្រតិបត្តិការសឹករងស្រុកម៉ាឡៃ បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់បានចំនួន០៥នាក់ ១.ឈ្មោះ [redacted] សីហា ២.ឈ្មោះ [redacted] ធឿន ៣.ឈ្មោះ [redacted] ម៉ៅ ៤.ឈ្មោះ [redacted] ផាលី និង៥.ឈ្មោះ [redacted] វណ្ណៈ ដែលជិះរថយន្តមួយគ្រឿង ម៉ាកកាមេរីពាក់ផ្លាកលេខ ភ្នំពេញ 2F-5584 បើកបរដោយឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ៤០ឆ្នាំ ក្នុងគោលបំណងទៅស្រុកម៉ាឡៃដើម្បីឆ្លងដែនទៅប្រទេសថៃ។ ដោយឈ្មោះ [redacted] **សម្បត្តិ** បានយកកំរៃ ដឹកក្នុងមួយនាក់ចំនួន ៥០០បាត ដែលតម្លៃ ១២០បាតប៉ុណ្ណោះ ។ ក្នុងប្រតិបត្តិការនោះសមត្ថកិច្ចបានឃាត់ ខ្លួនជនល្មើសម្នាក់ឈ្មោះ [redacted] សម្បត្តិ (អ្នកបើកបរ) ដែលជាមេខ្យល់នាំពលករឆ្លងដែនទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ ។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនជនល្មើសមកកាន់អយ្យការ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

បានឃើញ : ដីកាសន្និដ្ឋានស្ថាពរលេខ : ២៧៦ អ.យ.ច ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១។

បានឃើញ : ដីកាដំណោះស្រាយលេខ : ១៧៧៧ ពស.ព្រស "យ"/២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២១។

បានឃើញ : ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ : ៣១០ ពស.ព្រជ "ក"/២១ ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០២១។

បានឃើញ : ឯកសារនានាក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ : ៣៤៩ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១។

បានឃើញ : ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដែលធ្វើឡើងអនុលោមតាមបញ្ញត្តិមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## នាពេលសវនាការ :

- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ**

- ក្រោយពីបាន ពិនិត្យឯកសារ និង ភស្តុតាងនានាដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបាន ស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបាន ពិនិត្យ និងពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

**យល់ឃើញថា** :

១.តាមរយៈដីកាដំណោះស្រាយ លេខ : ១៧៧៧ ពស.ព្រស-ឃ-/២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** ភេទប្រុស អាយុ ៤០ឆ្នាំ មកធ្វើការជំនុំជម្រះពីបទ "**ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**" ប្រព្រឹត្តនៅចំណុច ភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** បានឆ្លើយបដិសេធនាពេលសវនាការថា : ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ខ្លួនបានចេញពីស្រុកសំពៅលូនទៅខេត្តបន្ទាយមានជ័យ ដើម្បីរត់តាក់ស៊ី ។ ខណៈពេលដែលខ្លួនជិះដល់ខេត្តបន្ទាយមានជ័យ ខ្លួនក៏បានចុះដាក់ឥវ៉ាន់នៅផ្សារថ្មី។ បន្ទាប់ពីដាក់ឥវ៉ាន់រួចហើយក៏បានទៅឈប់នៅបេនឡានចាស់ដើម្បីចាប់ម៉ូយ ។ លុះមកដល់វេលាម៉ោងប្រហែលបួនរសៀល នាថ្ងៃខែឆ្នាំដដែល ស្រាប់តែមានមនុស្សជិះម៉ូតូមួយគ្រឿងមកសួរខ្លួនថា បងឡាននិងបងឯងរត់ទៅផ្លូវណា? ខ្លួនក៏ឆ្លើយថារត់ទៅសាស្តាបង ហើយសួរខ្លួនថាយកតម្លៃប៉ុន្មាន? ព្រោះពួកគាត់ចង់ទៅធ្វើការដាំដំឡូងនៅភូមិប៉ៀនទ្រេត ហើយខ្លួនឆ្លើយថា ក្នុងម្នាក់ យកថ្លៃចំនួន ៣០.០០០(បីម៉ឺនរៀល) និងបានសុំនាមប័ណ្ណខ្លួន ហើយជិះម៉ូតូទៅបាត់តែម្តង។ ក្រោយមកមានលេខទូរសព្ទ ០៦៦ ៨០ ៥៩ ២៣ បានទូរសព្ទមកខ្លួនឱ្យទៅយកគាត់នៅចំណុចផ្លូវចូលវត្តបត់គ្រង់មានគ្នា ចំនួន០២នាក់ ។ ខ្លួនបានបើកឡានទៅយកពួកគាត់មកបេនឡានវិញ ហើយមានម៉ូតូកង់បី បានជិះមកប្រាប់ ខ្លួនឱ្យយកមនុស្សបីនាក់ទៀតនៅជិតភ្លើងស្តុបផ្លូវចូលផ្សាររាត្រី ដោយពួកគាត់បានឱ្យថ្លៃខ្លួន ក្នុងម្នាក់ចំនួន ៥០០(ប្រាំរយ)បាត។ លុះមកដល់វេលាម៉ោងប្រាំបួនយប់ខ្លួនបានឌុបពួកគាត់ទាំងប្រាំនាក់ ដល់ចំណុច បឹងបេងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ស្រាប់តែមានគេទូរស័ព្ទមកអ្នកជិះក្នុងឡានម្នាក់ ហើយបានឱ្យខ្លួនឈប់ឡាននឹងពួកគាត់ចំនួនពីរនាក់បានចុះពីរលើឡានហើយរត់គេចខ្លួនបាត់ បន្ទាប់មកក៏មានសមត្ថកិច្ចមកដល់ឃាត់ខ្លួនតែម្តង។ ពេលសមត្ថកិច្ចឃាត់ខ្លួន សមត្ថកិច្ចបានដកហូតរថយន្តចំនួន០១ គ្រឿងម៉ាកកាំរ៉ៃ ស៊េរីឆ្នាំ១៩៩៥ ពាក់ផ្លាកលេខភ្នំពេញ 2F-5584 ទូរស័ព្ទចំនួន០១គ្រឿងម៉ាកVivo ពណ៌ស។ ខ្លួនមិនបាននាំមនុស្សឆ្លងដែនខុសច្បាប់ឡើយ ព្រោះខ្លួនគ្រាន់តែជាអ្នករត់តាក់ស៊ីធម្មតាតែប៉ុណ្ណោះ លុះពេលសមត្ថកិច្ចឃាត់ខ្លួន ទើបខ្លួនដឹងថាភ្ញៀវដែលអង្គុយនៅក្នុងឡាន គឺគឺមានបំណងទៅធ្វើការនៅប្រទេសថៃ។ នៅក្នុងរឿងនេះខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាលើកលែងទោសដល់រូបខ្លួនផង។

៣.តាមរយៈចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** បានឆ្លើយថា ខ្លួនមិនបាននាំមនុស្សឆ្លងដែនទៅធ្វើការដាំដំឡូងនៅប្រទេសថៃឡើយ គឺខ្លួនគ្រាន់តែជាអ្នករត់តាក់ស៊ីធម្មតាតែប៉ុណ្ណោះ ចម្លើយនេះអាចឱ្យ



Scanned with CamScanner

តុលាការជឿជាក់បាន ដោយហេតុថាជនជាប់ចោទមានមុខរបរជាអ្នករត់តាក់ស៊ីធម្មតា ហើយមុននឹងធ្វើការដឹកភ្ញៀវ ជនជាប់ចោទបានធ្វើការដឹកឥវ៉ាន់សំពីងសំពោងឱ្យភ្ញៀវដទៃទៀតយកទៅភូមិសាស្ត្រ សាស្តា ដែលជាគោលដៅ មិនមែននាំមនុស្សឆ្លងដែននោះឡើយ ការណ៍នេះសរបញ្ជាក់ ឱ្យតុលាការឃើញថា ជនជាប់ចោទពិតជាមិនបាន ប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។

៤.តាមរយៈទង្វើ និងសកម្មភាពរបស់ជនជាប់ចោទ បានបង្ហាញថា ជនជាប់ចោទមានមុខរបរជាអ្នក រត់តាក់ស៊ីប្រចាំថ្ងៃ ដែលជាមុខរបរត្រូវតែដឹកមនុស្ស ហើយទទួលបានកម្រៃសេវាថ្លៃដឹកតម្លៃទីផ្សារធម្មតា ដោយ គ្មានចេតនា ឬការបម្ភិតបម្ភំពីអ្នកដទៃក្នុងការនាំមនុស្សចេញក្រៅពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ ឃើញថាចរិតលក្ខណៈរបស់ជនជាប់ចោទ សរបញ្ជាក់ឱ្យតុលាការឃើញថា ជនជាប់ចោទពុំមានគោលដៅនាំ យកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា នោះទេ ដែលពុំមានធាតុផ្សំគ្រប់គ្រាន់នៃបទល្មើស "**ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**" ដូចមានចែង តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នោះឡើយ ។ **យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** បានបញ្ញត្តិថា **វិមតិសង្ស័យត្រូវ បានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច** គប្បីតុលាការសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** រួចខ្លួនពី បទចោទប្រកាន់នេះ ។

៥.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : តាមចម្លើយរបស់ជនជាប់ចោទ ព្រមទាំងភស្តុតាង ផ្សេងៗដែលមាននៅក្នុងសំណុំរឿង សរបញ្ជាក់ឱ្យឃើញថា ពុំមានករណី "**ការនាំយកចេញដោយមិនស្រប ច្បាប់សម្រាប់នាំឆ្លងដែន**" ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** នោះឡើយ។ ដូចនេះប្តឹងសុំ ឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចទៅតាមច្បាប់ ជាការសន្និដ្ឋានគប្បីពិចារណា។

៦.លោក [redacted] និងលោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ដោយហេតុថាកូន ក្តីរបស់ខ្លួនមានមុខរបរជាអ្នករត់តាក់ស៊ីធម្មតា ដឹកឥវ៉ាន់ផ្សេងៗទៀតមិនអាចប្រកបរបរនាំមនុស្សឆ្លងដែនខុស ច្បាប់ឡើយ ខ្លួនសំណូមសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាឱ្យកូនក្តីរបស់ខ្លួនរួចខ្លួនពីបទចោទប្រកាន់នេះផង គប្បីតុលាការនឹងលើកយកមកពិនិត្យ និងពិចារណាតាមផ្លូវច្បាប់។

**៧.**គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សម្បត្តិ** ភេទប្រុស អាយុ ៤០ឆ្នាំ ពីបទ "**ការនាំយក ចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**" ប្រព្រឹត្តនៅចំណុចភូមិត្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញ ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**៨.វត្ថុតាងដែលដកហូតមាន :**

.រថយន្តចំនួន០១ គ្រឿងម៉ាកកាំមេរី ស៊េរីឆ្នាំ១៩៩៥ ពណ៌ស លេខតួ SXV10-0282939 ពាក់ផ្លាកលេខភ្នំពេញ 2F-5584 ។

.ទូរសព្ទចំនួន០១គ្រឿងម៉ាក VIVO ពណ៌ខ្មៅ-ខៀវ IMIE1: 863229044601459 IMIE2: 863229044601442 ។



Scanned with CamScanner

ដែលបានដកហូតពីឈ្មោះ [redacted] **សម្បត្តិ** រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **គប្បីប្រគល់ឱ្យម្ចាស់ដើមវិញ** ។

## ហេតុដូចនេះសម្រេច

I. **ឱ្យជនជាប់ចោទឈ្មោះ** [redacted] **សម្បត្តិ** ភេទប្រុស អាយុ ៤០ឆ្នាំ សញ្ជាតិខ្មែរ ជានីតិជន ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ស្ពឺ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិគីឡូ១៣ (ឃុំមិនស្គាល់) ស្រុកសំពៅលូន ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] បៀង "រស់" ម្ដាយឈ្មោះ [redacted] ឡាំ "រស់" ប្រពន្ធឈ្មោះ [redacted] សុឃីម មានកូនចំនួន០១នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ២៤៩ ព្រ.ទ/III"ឃ"/២១ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១)

**រួចខ្លួនពីបទ "ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន"** ប្រព្រឹត្តនៅចំណុចភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

II. **វត្ថុតាងដែលដកហូតមាន** :

១.រថយន្តចំនួន០១ គ្រឿងម៉ាកកាំមេរី ស៊េរីឆ្នាំ១៩៩៥ ពណ៌ស លេខតួ SXV10-0282939 ពាក់ផ្លាកលេខភ្នំពេញ 2F-5584 ។

២.ទូរសព្ទចំនួន០១គ្រឿងម៉ាក VIVO ពណ៌ខ្មៅ-ខៀវ IMIE1: 863229044601459 IMIE2: 863229044601442 ។

ដែលបានដកហូតពីឈ្មោះ [redacted] **សម្បត្តិ** រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ** ។

I. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សម្បត្តិ** ។ បើកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់របស់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]